# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Jun-2011, 13:43
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់ អៀង សារី សុំការអនុញ្ញាតដើម្បីដាក់សារណាបន្ថែមរបស់ខ្លួន ចំពោះអញ្ញត្រកម្មតាមវិធាន ៨៩ (ខ្ទង់កិច្ចកម្មតាមច្បាប់ជាតិ)

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះស្នើសុំអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យគាត់បន្ថែមទៅលើអញ្ញត្រកម្មតាមវិធាន៨៩ របស់គាត់ទាក់ទងនឹងយុត្តាធិការរបស់ អវតក ដើម្បីអនុវត្តមាត្រា ៣ថ្មី នៃច្បាប់បង្កើត អវតក (ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ) ។ ជាជម្រើសមកវិញ មេធាវីការពារក្តីស្នើសុំនូវពេលវេលាគ្រប់គ្រាន់ដើម្បីបន្ថែមអញ្ញត្រកម្មនេះនៅសវនាការបឋម តាមរយៈសារណាផ្ទាល់មាត់ ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពិព្រោះមានបញ្ហាច្បាប់នៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលមិនត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា ដែលមេធាវីការពារក្តីយល់ឃើញថា-ជាផ្នែកនៃកាតព្វកិច្ចដែលប្រកបដោយវីរិយភាពរបស់ខ្លួន- បញ្ហាច្បាប់ទាំងនេះត្រូវតែបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅមុនដំណើរការជំនុំជម្រះក្តី ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់បន្ថែមទៀត ដោយក្រែងលោអំណះអំណាងលើកមុនដែលធ្វើឡើងដោយមេធាវីការពារក្តី ត្រូវបានគេចាត់ទុកថាជាការលះបង់ចោល ។

## មូលដ្ឋានសម្រាប់សំណើ

១. មេធាវីការពារក្តី មិនអាចលើកឡើងនូវការភ័ន្តច្រឡំជាក់លាក់នៅក្នុងការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះបានទេ ដោយសារតែមេធាវីការពារក្តីត្រូវតម្រូវឲ្យដាក់អញ្ញត្រកម្មរបស់ខ្លួននៅមុនការទទួលបានសាលដីកាមានសំអាងហេតុរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ។ កាលពីលើកមុនអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងមកមេធាវីការពារក្តីថា ដោយសារតែការប៉ះពាល់សិទ្ធិដែលបណ្តាលមកពីសេចក្តីសម្រេចគ្មានសំអាងហេតុដោយអង្គបុរេជំនុំជម្រះ ដូច្នេះជាគោលការណ៍សារណាបន្ថែមអាចទទួលយក ប៉ុន្តែអង្គជំនុំជម្រះនឹងណែនាំក្រុមមេធាវីការពារក្តីបន្ថែមទៀតទាក់ទងនឹងចំនួនទំព័រ និងពេលវេលាកំណត់ បន្ទាប់ពីទទួលបានការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ[2] ។ បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសំអាងហេតុ អង្គជំនុំជម្រះស្នើឲ្យសហព្រះរាជអាជ្ញា "បង្ហាញមូលដ្ឋាននៃអំណះអំណាងដែលខ្លួនដែលថា បទល្មើសតាមច្បាប់ជាតិមិនត្រូវបានរារាំងដោយអាជ្ញាយុកាល ពាក់ព័ន្ធនឹងជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង ០០២" ហើយអនុញ្ញាតឲ្យមេធាវការពារក្តីឆ្លើយតប

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ D427/1/30 ។

[2] សូមមើលសារអេឡិចត្រូនិករបស់អ្នកនាង Tanya Pettay ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១១ បានបញ្ជាក់ពីចំណុចនានាដែលបានលើកឡើងនៅកិច្ចប្រជុំ និងបានបន្ថែមការស្រាយបភ្លឺបន្ថែមមួយចំនួន និងការឆ្លើយតបរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

ចំពោះសារណានេះ[3] ។ សហព្រះរាជអាជ្ញាមិនបានលើកឡើងនូវការភ័ន្តច្រឡំជាក់លាក់ដោយអង្គបុរេជំនុំជម្រះទេ ហើយដូច្នេះមេធាវីការពារក្ដីនឹងមិនអាចលើកឡើងនូវបញ្ហាទាំងអស់នេះនៅក្នុងចម្លើយតបរបស់ខ្លួនដែរ ។

**សំណើ**

២. មេធាវីការពារក្ដី ស្នើសុំដាក់សារណាបន្ថែមដាច់ដោយឡែកមួយទៅនឹងអញ្ញត្រកម្មរបស់ខ្លួនទាក់ទងនឹងយុត្តាធិការរបស់ អវតក ទៅលើឧក្រិដ្ឋកម្មតាមច្បាប់ជាតិ ដែលនឹងលើកឡើងនូវការភ័ន្តច្រឡំនៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដូចខាងក្រោម៖

ក. អង្គបុរេជំនុំជម្រះភ័ន្តច្រឡំនៅក្នុងការយល់ឃើញថាលោក អៀង សារី អាចបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិ ខណៈដែលសហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាចំពោះភាពអាចអនុវត្តបានរបស់វា[4] ។ ចំណាត់ការត្រឹមត្រូវដើម្បីគោរពសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ដែលត្រូវសន្មតជាមុនថាគ្មានទោស នោះគឺមិនត្រូវចោទប្រកាន់លោក អៀង សារី ចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិនោះទេ ហើយ

ខ. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំក្នុងការយល់ឃើញថាការអនុវត្តមាត្រា ៣ថ្មី មិនរំលោភបំពានលើសិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានប្រព្រឹត្តស្មើៗគ្នានៅចំពោះមុខច្បាប់[5] មាត្រា ៣ថ្មី នៃច្បាប់បង្កើត អវតក ពន្យារពេលយុត្តាធិការនៃបទល្មើសមនុស្សឃាត ទារុណកម្ម និងការធ្វើទុកបុកម្នេញខាងសាសនានៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ តែនៅពេលដែលបទល្មើសទាំងនេះត្រូវបានចោទប្រកាន់នៅ អវតក តែប៉ុណ្ណោះ ។ ការអនុវត្តមាត្រានេះរំលោភសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ដែលត្រូវទទួលការប្រព្រឹត្តស្មើៗគ្នា ។

**ដូច្នេះ** អាស្រ័យដូចហេតុផលដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្ដីសូមស្នើដោយគោរពដល់

---

[3] សេចក្ដីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ E51/7 នៅទំព័រ ៧ ។

[4] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ នៅកថាខណ្ឌទី ២៧២-២៧៧ ។

[5] ដូចខាងលើ នៅកថាខណ្ឌទី២៨៨-២៩២ ។

អង្គជំនុំសាលាដំបូងអនុញ្ញាតឲ្យខ្លួនដាក់សារណាបន្ថែមរបស់ខ្លួន ទៅលើបញ្ហាអញ្ញត្រកម្មតាមវិធាន ៨៩ (ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ) ឬជាជម្រើសមកវិញ អនុញ្ញាតឲ្យមានឱកាសគ្រប់គ្រាន់ដើម្បីលើកបញ្ហាទាំងនេះនៅសវនាការបឋម ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៨** ខែ **មិថុនា** ឆ្នាំ **២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**